# វប្បធម៌និងឧបករណ៍តន្ត្រីធ្វើពីលោហធាតុនៃប្រទេសកម្ពុជា

កម្ពុជា ជាព្រះរាជាណាចក្រនៃវប្បធម៌ ប្រកបដោយវប្បធម៌និងអរិយធម៌កំពូលរុងរឿង សម្បូណ៌បែប មានសិល្បៈទស្សនីយភាពដាច់ម្តែទម្រង់ ឧបករណ៍តន្ត្រីជាច្រើនមួយរយដែលខ្មែរបាននិងកំពុងប្រើប្រាស់នៅក្នុងវង់តន្ត្រីជាច្រើនម្ភៃវង់។ ភាពសម្បូណ៌ ហូរហៀរនៃឧបករណ៍តន្ត្រីនេះ គឺដោយសារកត្តាមួយចំនួន រួមមានកត្តាធម្មជាតិ មានដីឥដ្ឋ ឫស្សី ឈើ រុក្ខជាតិ ដែក ស្ពាន់ លង្ហិន មាស ប្រាក់ ជ័រ ស្បែក សក់ ឆ្អឹង ក្លុក និងសម្បកខ្យងជាដើម ដែលខ្មែរយើងយកមកច្នៃផលិតទៅជាឧបករណ៍តន្ត្រី។

«វប្បធម៌ស្ពាន់កម្ពុជា» មានអាយុកាលមុនសម័យគ្រឹស្តសករាជ្យ គឺសម័យបុរេប្រវត្តិសាស្ត្រ។ តឹកតាងបុរេប្រវត្តិសាស្ត្រ បានបន្សល់ទុកដល់បច្ចុប្បន្ននូវ រនាតថ្ម ស្គរមហោរធឹក ស្គរហៅទឹកភ្លៀង ជួង គ្រឿងតុបតែង របស់ប្រើប្រាស់ប្រចាំថ្ងៃ ប្រាសាទបុរាណ និងសិលាចារឹក ដែលផ្តល់ឱ្យយើងជាអំណះអំណាង អំពីវត្តមានជាក់ស្តែង និងប្រវត្តិសាស្ត្រដ៏វែង និងយូរលង់នៃវប្បធម៌ស្ពាន់របស់ខ្មែរ។ ភស្តុតាងទាំងនេះ យើងបានរកឃើញនៅក្នុងតំបន់បុរាណវិទ្យាខ្មែរនៅ សម្រោងសែន និងអន្លង់ផ្តៅ ខេត្តកំពង់ឆ្នាំង ក្បាលរមាស ខេត្តព្រះវិហារ ល្អាងស្ពាន ខេត្តបាត់ដំបង ស្រែស្បូវនិងភ្នំរលួស ខេត្តក្រចេះ និងមេមត់ ខេត្តកំពង់ចាម ។(១)(២)

សម័យអង្គរខ្មែរដ៏មហាលូតលាស់រុងរឿង (សតវត្សទី៩-១៥) បានបន្សល់ទុកនូវប្រាសាទបុរាណតូចធំជាងមួយពាន់ប្រាសាទ ដែលជាភស្តុតាងប្រវត្តិសាស្ត្រក្នុង រូបភាពជាចម្លាក់និងសិលាចារឹក អំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ព្រះមហាក្សត្រ និងប្រជាពលរដ្ឋសាមញ្ញ ជំនឿសាសនា ព្រមទាំងវត្តមានរបាំនិងតន្ត្រី មានឧបករណ៍ពិណ ខ្សែមួយ ស្រឡៃ ត្រែ ស្នែង ពាទ្យ គង ឆាប ឈឹង និងស្គរជាច្រើនប្រភេទ។

---

(១) ត្រឹង ង៉ារ ២០០៣[១៩៧៣]: ២២

(២) យុន សាម៉េន ២០០២: ៥៨

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ខ្មែរយើងប្រើឧបករណ៍ដែលបានរៀបរាប់ខាងលើ នៅក្នុងវង់តន្ត្រីបច្ចុប្បន្ន ដែលយើងអាចសន្និដ្ឋានបានថា ទម្រង់និងទ្រង់ទ្រាយប្រពៃណីតន្ត្រីខ្មែរបច្ចុប្បន្ននេះ ពិតជាមានប្រភពដើម និងមានការបន្តនូវប្រពៃណីតន្ត្រីពីសម័យអង្គរនិងមុនអង្គរមកម៉្លេះ។ ហើយខ្មែរជំនាន់ក្រោយអង្គរ ក៏មានការច្នៃប្រឌិតនិងអភិវឌ្ឍបន្ថែមទៅលើវប្បធម៌អង្គរថែមទៀត។

បើយើងសង្កេតទៅលើសំណេរ អត្ថបទ និងសៀវភៅជាច្រើនពាក់ព័ន្ធនឹង លោហធាតុ យើងឃើញថាខ្មែរប្រើពាក្យ «លង្ហិន» សម្រាប់ពាក្យអង់គ្លេស bronze និង brass ។[៣] តាមរយៈការសិក្សា ស្រាវជ្រាវ និងជំរឿនអំពីវប្បធម៌ស្ពាន់នៅកម្ពុជា ខ្ញុំរកឃើញថាមានឧបករណ៍តន្ត្រីចំនួន១៩ ដែលផលិតពីស្ពាន់ លង្ហិន ដែក និងលោហធាតុផ្សំ គឺស្មើនឹងប្រមាណ២០ភាគរយនៃឧបករណ៍តន្ត្រីខ្មែរទាំងអស់។ ឧបករណ៍ទាំងនេះមានដូចជា៖ ស្គរមហោរធឹក ឬ ស្គរមហាឫទ្ធិ ស្គរហៅទឹកភ្លៀង ដួង គងញី គងឈ្មោល គងម៉ង់ គងធំ គងតូច ឃ្មោះ ឆាប ឈឹង រនាតដែក រនាតថោង ពាទ្យ គងវង់តូច គងវង់ធំ កណ្ដឹង ចង្រ្កង់ និងអង្គួច (កង្គួច)។

តាំងពីបុរាណកាលមក តន្ត្រីខ្មែរនៅជាប់ជាមួយនឹងធម្មជាតិ កសិកម្ម និងពិធី បុណ្យទានប្រពៃណីនិងសាសនាផ្សេងៗនៅក្នុងជីវិតខ្មែរ ដូចជាពិធីបុណ្យកំណើត កោរជុកបំបួសនាគ អាពាហ៍ពិពាហ៍ បញ្ចុះនិងលៀងអារក្ខ សព រហូតដល់ព្រះរាជពិធីចម្រើនព្រះជន្មនិងគ្រងរាជ្យ។ ឯឧបករណ៍តន្ត្រីខាងលើ គឺគេប្រើប្រាស់នៅក្នុងវង់តន្ត្រីខ្មែរដ៏សម្បូណ៌បែបដែលពាក់ព័ន្ធនឹងជីវិតខ្មែរខាងលើនេះ។

ឧបករណ៍តន្ត្រីដែលធ្វើពីស្ពាន់ គឺនៅមានប្រើប្រាស់ក្នុងចំណោមជនជាតិដើមភាគតិចនៅកម្ពុជា ទោះបីនៅក្នុងកំរិតតិចតួចក៏ដោយ ដែលជាតម្រូវការដើម្បីកំដរ ពិធីប្រពៃណីផ្សេងៗ ដូចជាពិធីធ្វើចម្ការ ដាំស្រូវ ច្រូតស្រូវ សែនស្រូវ អាពាហ៍ពិពាហ៍ គ្រោះមហន្តរាយរោគនិងជំងឺ បញ្ចូលនិងលៀងអារក្ខ កាប់ក្របី និងសពជាដើម។ តាមរយៈការស្រាវជ្រាវ

[៣] Headley et al. 1977: 908

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ដែរ ខ្ញុំក៏សង្កេតឃើញថាជាការសោកស្ដាយមួយ ដែលជនជាតិភាគតិចយើងនៅកម្ពុជាមិនបានផលិតគង់ដោយខ្លួនឯងនិងបែរទៅទិញពីអ្នកជិតខាងយើងទៅវិញ។

នៅក្នុងន័យនេះ ខ្ញុំគិតថា ប្រសិនបើយើងមិននាំគ្នាបណ្ដុះសតិស្មារតីនិងមនសិការស្រឡាញ់វប្បធម៌ប្រពៃណីទាំងនេះ ហើយនាំគ្នាអភិរក្ស ថែរក្សា ស្រឡាញ់ គោរព តម្លៃ ការពារ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលជាបន្តនោះទេ សម្បត្តិវប្បធម៌នេះនឹងប្រឈមការបាត់បង់ ឬឱនថយនៅនាថ្ងៃអនាគតពុំខានឡើយ។ លើសពីនេះទៅទៀតយើង ជាពិសេសយុវវ័យបានកំពុងនឹងបន្តប្រឈមនឹងបរិបទសាកលភាវូបនីយកម្ម ដែលហូរចូលមកកម្ពុជាក្នុងទ្រង់ទ្រាយដ៏ធំ ប្រៀបបាននឹងទឹកបាក់ទំនប់ហូរចូលមកទាំងរឿងវិជ្ជមាននិងអវិជ្ជមានដែលយើងជាអ្នកទទួលត្រូវគិតពិចារណា ជ្រើសរើសយកអ្វីដែលជាផលប្រយោជន៍នាំមកនិងធ្វើឱ្យវប្បធម៌ប្រពៃណីរបស់យើងរីកចម្រើនទៅមុខ។

យើងគួរតែស្នើដាក់បញ្ចូលឧបករណ៍និងវង់តន្ត្រីគង ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនៃអង្គការយូណេស្កូ ដើម្បីជាការទទួលស្គាល់ថ្នាក់ជាតិនិងអន្តរជាតិពង្រឹងមនសិការនិងស្មារតីកូនខ្មែរ និងដើម្បីគាំទ្រ ទ្រទ្រង់អភិរក្ស ថែរក្សា ការពារ បណ្ដុះបណ្ដាល និងផ្សព្វផ្សាយ ដើម្បីលើកស្ទួយការពារ បន្តសម្បត្តិវប្បធម៌នេះ ទៅនាពេលអនាគតជានិរន្តន៍តរៀងទៅ។

## ឯកសារយោង

Headley, Robert, and et al. (1977). *Cambodian-English Dictionary*. Washington, DC: The Catholic University of America Press.

Khun, Samen. (2002). *The New Guide to the National Museum*. Phnom Penh: Ministry of Culture and Fine Arts.

Troeung, Ngea. (2003[1973]. *Khmer History* (2 vols.). Phnom Penh: Ministry of Education, Youth and Sport.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង







អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង